**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ ១១ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល

## ទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមសារាចររបស់រាជរដ្ឋាភិបាលលេខ ០១ សរ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០១០ ស្តីពីការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតគណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល សម្រាប់សម្របសម្រួល និងអនុវត្តដំណើរការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលនៅទូទាំងប្រទេស ក្នុងគោលដៅគ្រប់គ្រងធនធានមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ ក្នុងរដ្ឋបាលសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ង៉ោ ហុងលី** | អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២- ឯកឧត្តម **ឈួន នាម** | អគ្គលេខាធិការរង ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | អនុប្រធាន |
| ៣- ឯកឧត្តម **ប៉ុល ពីឌុ** | អគ្គលេខាធិការ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម **ខៀវ ច័ន្ទប៊ុនធឿន** | ប្រធាននាយកដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អនុប្រធាន |
| ៥- ឯកឧត្តម **អែម ប៊ុនថុល** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងជាប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោក **យក់ ប៊ុនណា** | ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- លោក **លី គីមសី** | ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៨- លោក **ថោង បូរ៉ាន់** | ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៩- លោក **ម៉ី សំបូរ** | ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក ក្រសួងសុខាភិបាល | សមាជិក |
| ១០- លោក **ម៉ី ហ៊ុល** | ប្រធាននាយកដ្ឋានទីស្តីការរដ្ឋបាលបុគ្គលិក ក្រសួងកិច្ចការនារី | សមាជិក |
| ១១- លោក **ថៃ ឧុទ្ធី** | អនុប្រធានក្តាប់រួមនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍនធនធានមនុស្ស ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

**ប្រការ២** : គណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ដើម្បីរៀបចំ និងអនុវត្តដំណើរការជំរឿនមន្ត្រីរាជការឱ្យទទួលបានជោគជ័យ
- រៀបចំសេចក្តីណែនាំលម្អិត អំពីកម្មវិធីការងារសម្រាប់ចាត់ចែងអនុវត្តជាក់ស្តែងព្រមទាំងនីតិវិធីនានានៃដំណើការអនុវត្តជំរឿនមន្ត្រីរាជការស៊ីវិល
- រៀបចំរបាយការណ៍ ស្តីពីការប្រព្រឹត្តទៅ និងលទ្ធផលនៃការជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ ។

**ប្រការ៣** : គណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល មានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលជាសេនាធិការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់បំពេញការងារ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិនា ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជា ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**<u>ចម្លងជូន</u>** :

-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលាខេត្ត-រាជធានី
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ